# អ្នកនាំសារ
## The Messenger

30
ខែមករា ឆ្នាំ២០០៦- ព័ត៌មានសម្រាប់ប្រើប្រាស់តែនៅក្នុងព្រះសហគមន៍កាតូលិកប៉ុណ្ណោះ






ការអភិវឌ្ឍន៍ទាមទារនូវការចូលរួមពីស្ត្រី
ទំព័រ ១០



២៤នាក់ ចូលក្នុងព្រះសហគមន៍កាតូលិក
ទំព័រ ៨

តើសុភមង្គលគ្រួសារស្ថិតនៅឯណា?
ទំព័រ ៩

# អភិបូជាថ្ងៃអាទិត្យ

## សំនួរក្មេងៗ




**តើហោរាចារ្យគឺជានរណាទៅ?**

ហោរាចារ្យពុំមែនជាស្តេចនោះទេ ប៉ុន្តែពួកគេគឺជាគ្រូទស្សទាយតាមតារា។ ពួកគេចាត់ទុកថា ផ្កាយនៅលើមេឃអាចជាប្រផ្នូលបង្ហាញអំពីព្រឹត្តិការណ៍សំខាន់ៗ ដែលកើតក្នុងពិភពលោកយើងនេះ។ នៅពេលពួកហោរាចារ្យឃើញផ្កាយ ដែលគេមិនធ្លាប់ស្គាល់ ពួកគេគិតថា ផ្កាយនេះគឺជាសញ្ញាសម្គាល់មួយបញ្ជាក់ថា នឹងមានព្រះមហាក្សត្រមួយអង្គដ៏អស្ចារ្យប្រសូតមក ជាហេតុការណ៍ចម្លែក។ ពួកហោរាចារ្យមិនមែនជាជនជាតិយូដាទេ។ ប៉ុន្តែព្រះយេស៊ូបានជ្រើសរើសអ្នកប្រាជ្ញទាំងនោះឱ្យធ្វើដំណើរ ដើម្បីស្វែងរកសេចក្តីពិត។ ពេលនោះពួកហោរាចារ្យក្រាបថ្វាយបង្គំព្រះឱរស ដែលគេមិនដែលស្គាល់។ ពួកគេថ្វាយមាស ដូចដែលគេធ្លាប់ថ្វាយចំពោះស្តេច។ គេថ្វាយគ្រឿងក្រអូប ដូចដែលគេធ្លាប់ថ្វាយចំពោះព្រះជាម្ចាស់ និងជ័រល្វីងទេសជាគ្រឿងសម្រាប់អប់សពកុំឱ្យស្អុយរលួយ។ គេថ្វាយតង្វាយទាំងនេះដោយទទួលស្គាល់ថា ទារកនេះជាព្រះឱរសមួយអង្គ ដែលយាងមកពីព្រះជាម្ចាស់។ តើមានហោរាចារ្យប៉ុន្មាននាក់? ក្នុងព្រះគម្ពីរគឺគ្មានបញ្ជាក់ចំនួនទេ។ គ្រីស្តបរិស័ទពីដើមសន្មតថា មានហោរា-ចារ្យតែបីនាក់ ព្រោះគេថ្វាយតង្វាយបីមុខ។ តែអ្នកនិពន្ធគម្ពីរដំណឹងល្អ មានបំណងចង់ពន្យល់ថា សាសន៍ដទៃសុខចិត្តធ្វើដំណើរទៅរកព្រះគ្រីស្ត រីឯជនជាតិយូដា ទោះបីគេទទួលព្រះគម្ពីរពីព្រះជាម្ចាស់ ទោះបីគេជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់ក្តី ក៏គេមិនព្រមធ្វើដំណើរទៅរកព្រះអង្គដែរ។ ជំនឿប្រៀបដូចជាការធ្វើដំណើរម្យ៉ាង។

P.R

### ថ្ងៃអាទិត្យ ទី១ ខែមករា ឆ្នាំ២០០៦

## “នាងម៉ារីចងចាំហេតុការណ៍ទាំងនេះទុកក្នុងចិត្ត...”

(លក ២,១៦-២១)

លោកលូកា ជាអ្នកនិពន្ធគម្ពីរដំណឹងល្អទីបី លោកសរសេរគម្ពីរជាងប៉ែតសិបឆ្នាំក្រោយពេលព្រះយេស៊ូប្រសូត។ លោកមានបំណងប្រកាសជំនឿរបស់ព្រះសហគមន៍ទៅលើព្រះយេស៊ូជាព្រះគ្រីស្ត និងជាព្រះអម្ចាស់។ ក្រុមគ្រីស្តទូតប្រកាសថា ព្រះយេស៊ូជាព្រះគ្រីស្ត និងជាព្រះអម្ចាស់ នៅពេលព្រះអង្គទទួលព្រះជន្មដ៏រុងរឿង បន្ទាប់ពីសោយទិវង្គតនោះ។ ក្រោយពីលោកយេស៊ូ ជាបុត្រទទួលព្រះជន្មថ្មីដ៏រុងរឿង “នាងម៉ារីចងចាំហេតុការណ៍ទាំងអស់ក្នុងចិត្ត ហើយរិះគិតពិចារណាថែមទៀតផង” គឺនាងរិះគិតអំពីអត្ថន័យនៃទុក្ខលំបាករបស់បុត្រ។ ពេលលោករៀបរាប់អំពីព្រះយេស៊ូប្រសូត លោកតែងរឿងមួយដើម្បីលាតត្រដាងជំនឿរបស់ព្រះសហគមន៍នៅពេលនោះ។ លោករៀបរាប់អំពីនាងម៉ារីទុកជាគ្រីស្តបរិស័ទដើមដំបូង និងជាគ្រីស្តបរិស័ទគំរូ។ នាងទទួលដំណឹងអំពីឋានៈកូនរបស់ខ្លួន ពីពួកគង្វាល ជាអ្នករស់នៅក្រៅសង្គមរបស់អ្នកកាន់សាសនាត្រឹមត្រូវ។ យើងក៏ដូចជានាងម៉ារីដែរ គឺយើងទទួលដំណឹងអំពីព្រះយេស៊ូទទួលព្រះជន្មដ៏រុងរឿង និងគង់នៅជាមួយយើងជារៀងរាល់ថ្ងៃ។ ព្រះអង្គក៏ប្រោសប្រទានឱ្យយើងទៅជាបុត្រធីតារបស់ព្រះបិតា។ តើសេចក្តីនេះមានអត្ថន័យយ៉ាងណាសម្រាប់យើងសព្វថ្ងៃ? យើងត្រូវតែចងចាំហេតុការណ៍ទាំងអស់នេះក្នុងចិត្ត ហើយរិះគិតពិចារណាថែមទៀតផង។

### ថ្ងៃអាទិត្យ ទី៨ ខែមករា ឆ្នាំ២០០៦

ព្រះយេស៊ូសម្តែងព្រះអង្គឱ្យមនុស្សលោកស្គាល់

## “យើងបានឃើញផ្កាយរបស់ព្រះអង្គ”

(មថ ២,១-១២)

លោកម៉ាថាយជាជនជាតិយូដាម្នាក់ និពន្ធគម្ពីររបស់លោក សម្រាប់ជនជាតិយូដាដូចគ្នា។ ក្នុងព្រះសហគមន៍របស់លោកនៅស្រុកស៊ីរី មានគ្រីស្តបរិស័ទពីរក្រុម គឺមួយក្រុមជាជនជាតិយូដា ដែលទទួលស្គាល់ព្រះយេស៊ូទុកជាព្រះគ្រីស្ត ដូចមានចែងក្នុងគម្ពីររបស់គេ ពួកគេយកចិត្តទុកដាក់កាន់តាមវិន័យលោកម៉ូសេ។ មានមួយក្រុមទៀត គឺជាសាសន៍ដទៃដែលមិនកាន់តាមធម្មវិន័យរបស់លោកម៉ូសេទេ។

លោកម៉ាថាយតែងរឿងនិទានអំពីហោរាចារ្យនេះឡើង ដើម្បីពន្យល់អំពីមូលហេតុដែលសាសន៍យូដាបដិសេធមិនព្រមទទួលស្គាល់ព្រះយេស៊ូទុកជាព្រះគ្រីស្ត រីឯហោរាចារ្យគឺជាសាសន៍ដទៃដែលជនជាតិយូដាធ្លាប់មើលងាយនាំគ្នាជឿលើព្រះអង្គវិញ។ ជនជាតិយូដាមានទាំងគម្ពីរ (ធម្មាចារ្យ) មានទាំងព្រះវិហារ (បូជាចារ្យ) និងមានព្រះមហាក្សត្រជាតំណាងព្រះជាម្ចាស់។ តែគេមិនព្រមចេញដំណើរទេ គេនៅតែកាន់ប្រពៃណីជាតិសាសន៍របស់គេ។ រីឯសាសន៍ដទៃវិញ ទោះបីគេជាអ្នកបាបក្តី ដែលគ្មានជំនឿ (គឺរកស៊ីនៅពេលយប់) គេសុខចិត្តចេញដំណើរស្វែងរកព្រះគ្រីស្ត។ ជនជាតិយូដាស្មានថា ខ្លួនបានសព្វគ្រប់ហើយនៅហ្នឹងកន្លែង។

រឿងនេះជារឿងរបស់យើងដែរ ជំនឿនាំឱ្យយើងផ្លាស់ប្តូរគំនិត កុំស្មានថាយើងមានជំនឿម្តងជាស្រេចនោះ យើងត្រូវខំដើរទៅរកព្រះគ្រីស្តដោយមិនឈប់ឈរឡើយ។ យើងមិនមែនជាគ្រីស្តបរិស័ទពេញលក្ខណៈម្តងជាស្រេចទេ គឺត្រូវស្វែងរកព្រះគ្រីស្តជានិច្ច!។



### ថ្ងៃអាទិត្យ ទី១៥ ខែមករា ឆ្នាំ២០០៦

## “តើលោកគ្រូនៅកន្លែងណា? -សូមអញ្ជើញ អ្នកនឹងឃើញ”

(យហ ១,៣៥-៤២)

លោកយ៉ូហាន ជាសាវ័ករបស់ព្រះយេស៊ូ រៀបរាប់អំពីដំណើរនៃជំនឿរបស់លោក។ មុនដំបូង លោកស្តាប់នូវពាក្យសំដីរបស់លោកយ៉ូហាន បាទីស្ត ជាអ្នកធ្វើពិធីជ្រមុជទឹក គឺលោកនេះប្រកាសសេចក្តី ដូចដែលព្រះសហគមន៍ធ្លាប់ប្រកាសមកយើងនៅពេលក្រោយ គឺ ព្រះយេស៊ូបូជាព្រះជន្មដូចកូនចៀម ដែលគេបូជាធ្វើជាយញ្ញ ដើម្បីឱ្យបានរួចពីបាប។ កូនសិស្សលោកពីរនាក់ចេញដំណើរ គឺឃ្លាតពីលោកទៅតាមព្រះអង្គ ដូចយើងដែរ ដែលចាកចេញពីទម្លាប់សាសនាទៅតាមព្រះយេស៊ូ។ ព្រះយេស៊ូងាកមកសួរ “តើអ្នកទាំងពីរមករកអ្វី?”។ ព្រះអង្គក៏ងាកមកសួរយើងដែរថា: “តើអ្នកជឿលើខ្ញុំដោយចង់បានអ្វី?” -“តើលោកនៅឯណា?” ព្រះអង្គអញ្ជើញយើងម្នាក់ៗ ឱ្យមករស់នៅជាមួយព្រះអង្គ។ យើងក៏មានបទពិសោធន៍ម្យ៉ាង រស់នៅជាមួយព្រះយេស៊ូ ដែលគង់នៅជាមួយព្រះបិតា។ ក្រោយមក លោកអន់ដ្រេក៏រត់ទៅហៅបងសិលា: “យើងរកព្រះគ្រីស្តឃើញហើយ!”។ ព្រះគ្រីស្តជាអ្នក ដែលផ្តល់សុភមង្គលដ៏ពិតប្រាកដឱ្យមនុស្ស។ តើព្រះយេស៊ូប្រទាននូវសេចក្តីសុខសាន្តឱ្យខ្លួនយើងបានយ៉ាងណា? បើសិនយើងបានសេចក្តីសុខសាន្ត យើងក៏សូមចែកអំណរសប្បាយរបស់ខ្លួនទៅឱ្យអ្នកដទៃដែរ។

ជំនឿពុំមែនជាទ្រឹស្តី មិនមែនជាសេចក្តី ដែលយើងរៀន និងចងចាំទេ។ ជំនឿគឺជារបៀបរស់នៅរួមជាមួយព្រះយេស៊ូ ដែលនាំយើងឱ្យទាក់ទងជាមួយព្រះបិតា។ តើព្រះយេស៊ូពិតជា “ព្រះគ្រីស្ត” ដែលផ្តល់សេចក្តីសុខតាមផ្លូវចិត្តឱ្យយើងយ៉ាងណា?

### ថ្ងៃអាទិត្យ ទី២២ ខែមករា ឆ្នាំ២០០៦

## “ចូរប្រែចិត្តគំនិត ហើយជឿដំណឹងល្អចុះ!”

(មក ១,១៤-២០)

ដំណឹងល្អ! ដំណឹងល្អ! គឺជាព័ត៌មានមួយផ្តល់ឱ្យបានសេចក្តីសុខសាន្ត បានសុភមង្គល បានសប្បាយរីករាយ។ តើព្រះយេស៊ូនាំដំណឹងល្អណាខ្លះមកមនុស្សលោក? តើយើងប្រកាសដំណឹងល្អណាខ្លះចំពោះជនជាតិកម្ពុជា នាបច្ចុប្បន្នកាលនេះ?

ព្រះយេស៊ូទើបទទួលពិធីជ្រមុជទឹក ពេលនោះ “មេឃហែក” បានសេចក្តីថា ព្រះជាម្ចាស់សម្តែងព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គមកដល់មនុស្សលោក។ ព្រះអង្គយកព្រះហឫទ័យទុកដាក់នឹងមនុស្សលោក! នរណាក៏ដោយ ទោះជាអ្នកបាបក្តី ក៏អាចទៅជាបុត្រធីតារបស់ព្រះបិតាបានដែរ។ អ្នករួមរស់ជាមួយព្រះយេស៊ូ ដោយផ្ញើជីវិតទាំងស្រុងលើព្រះអង្គ ក៏មានផ្លូវទៅកាន់ព្រះបិតាបាន។ ជីវិតយើងមានតម្លៃ! មនុស្សយើងលែងស្ថិតនៅក្រោមអំណាចនៃបាប ឬកម្មពៀរវេរាទៀតហើយ! យើងលែងមើលខ្លួនយើង ឬលែងនឹកនាពីអតីតកាលដ៏អាក្រក់ទៀតហើយ គឺយើងបែរមុខទៅរកព្រះយេស៊ូ ដែលនាំយើងទៅកាន់ព្រះបិតា ដែលស្រឡាញ់យើងវិញ។ ព្រះអង្គត្រាស់ហៅយើងទាំងអស់គ្នាឱ្យលះបង់របៀបរស់នៅចាស់ ហើយឱ្យដើរតាមព្រះយេស៊ូ គឺឱ្យរស់នៅតាមរបៀបថ្មី។ យើងត្រូវនៅរកស៊ីចិញ្ចឹមជីវិតដូចមុនមែន តែយើងរស់នៅដោយរបៀបប្លែកពីមុនដោយបែរមុខទៅរកព្រះបិតា ដែលស្រឡាញ់យើងជាដរាប។

**សូមថ្លែងអំណរគុណដល់ក្រុមការងារមណ្ឌលវប្បធម៌កាតូលិកដែលជួយសហការយ៉ាងកក់ក្តៅ!**



## លិខិតជូនប្រិយមិត្តអ្នកអាន “អ្នកនាំសារ” ក្នុងឱកាសឆ្នាំថ្មី ឆ្នាំ២០០៦!

បងប្អូនជាទីស្រលាញ់! ក្រុមការងារនៃការិយា-ល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍មានកិត្តិយសសូមជម្រាបសួរបងប្អូន ដោយក្តីស្រលាញ់ ដែលមកពីព្រះគ្រីស្តយេស៊ូ។ នៅក្នុងឆ្នាំថ្មីនេះ លោកអភិបាលទាំងបី បានប្រកាសកាលពីថ្ងៃទី៤ ខែធ្នូថា “ឆ្នាំថ្មី ជាឆ្នាំអរព្រះគុណព្រះជាម្ចាស់” ដែលព្រះអង្គបានចាត់ឱ្យមានក្រុមសាសនទូតនាំដំណឹងល្អ ចូលមកព្រះរាជាណាចក្រកម្ពុជាយើងរយៈពេល ៤៥០ឆ្នាំមកហើយ។ ហេតុនេះអ្នកនាំសារ សូមអញ្ជើញបងប្អូនដើម្បីរួមគ្នាអធិដ្ឋាន អរព្រះគុណព្រះជាម្ចាស់ និងសូមព្រះអង្គប្រទានឱ្យយើងទាំងអស់គ្នា ចេះរស់នៅធ្វើជាសាក្សីរបស់ព្រះគ្រីស្ត នៅតាមកន្លែងរៀងៗខ្លួន ហើយនិងបន្តបេសកកម្មរបស់គ្រីស្តទូតក្នុងការប្រកាស ដំណឹងល្អ អំពីសន្តិភាព យុត្តិធម៌ សេចក្តីស្រលាញ់ គ្មានអំពើហិង្សា អំណរសប្បាយ និងសុភមង្គលទៅដល់បងប្អូនដទៃទៀតនៅគ្រប់ទីកន្លែងតាមព្រះបន្ទូលរបស់ព្រះយេស៊ូគ្រីស្តជាអម្ចាស់នៃយើង។

បងប្អូនជាទីស្រលាញ់! សម្តេចប៉ាបបេណេឌីកទី១៦ បានលើកឡើងនូវប្រធានបទស្តីអំពីសេចក្តីពិត និងសន្តិភាពយកមកឱ្យព្រះសហគមន៍រិះគិតនៅក្នុងឱកាសទិវាសន្តិភាពពិភពលោក ថ្ងៃទី១ មករា ក្នុងឆ្នាំថ្មី ឆ្នាំ២០០៦នេះ ដោយព្រះអង្គសង្ឃឹមថា ពិភពលោកនឹងពោរពេញដោយភាពសុខសាន្ត និងសន្តិភាព។ អ្នកនាំសារ សូមរំឭកថា តើយើងខ្ញុំម្នាក់ៗ ធ្លាប់បានកសាងសន្តិភាពហើយឬនៅ? សន្តិភាពមានន័យយ៉ាងដូចម្តេចតាមជំនឿរបស់ខ្ញុំ? នាឱកាសចូលឆ្នាំថ្មីនេះ អ្នកនាំសារ សូមថ្លែងអំណរគុណនូវរាល់ការគាំទ្ររបស់បងប្អូនទាំងអស់ ដែលបានយកអស់កម្លាំងកាយ និងកម្លាំងចិត្តចំពោះ អ្នកនាំសារអស់រយៈពេល ១ឆ្នាំ កន្លងមកនេះ។ សូមព្រះជាម្ចាស់ប្រទានពរដល់បងប្អូនទាំងអស់គ្នា។

សួស្តីឆ្នាំថ្មី ឆ្នាំ២០០៦!

# បណ្ណាល័យថ្មី



Photo: L. Sovanna

បណ្ណាល័យមួយខ្នងជាអំណោយនៃសមាគមសាមគ្គីកសិករក្រីក្រស្រុកអង្គស្នួល ត្រូវបានសម្ពោធបើកឱ្យប្រើប្រាស់កាលពីថ្ងៃទី២៣ ធ្នូ ក្រោមអធិបតីភាពរបស់ឯកឧត្តម សក់ ស៊ីថា អគ្គនាយកនៃនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ។ បងស្រី ដានីស ប្រធានអង្គការ ជេ អេស ស៊ី ចាប់អារម្មណ៍ថាៈ “បងស្រីសប្បាយរីករាយណាស់ដោយមានបណ្ណាល័យថ្មី ដែលមានសៀវភៅជាច្រើនអប់រំអំពីសីលធម៌ និងការបំបាត់អំពើហិង្សា”។ ឯកឧត្តមសក់ ស៊ីថា បានកោតសរសើរដល់សមាគមដោយបញ្ជាក់ថាៈ “ដើម្បីការអភិវឌ្ឍន៍រីកចម្រើន ត្រូវឱ្យមានការចូលរួមពីសហគមន៍សង្គមស៊ីវិលជាមួយរដ្ឋាភិបាល”។ សុវណ្ណា

# យើងជាមិត្តសំលាញ់នឹងគ្នា


Photo: L. Sovanna

បន្ទាប់ពីពិធីសម្ពោធព្រះវិហារ និងទទួលបងប្អូនចូលក្នុងជំហាន ទី១ នៅឯព្រះសហគមន៍កអណ្តើក នាឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង លោកអគ្គរាជទូតក៏បានទៅធ្វើទស្សនកិច្ចនៅព្រះសហគមន៍អ្នកលឿង។ លោកឪពុកប៉ុងសួងស៍ បានជម្រាបពីដំណើរការរបស់ព្រះសហគមន៍ និងការខិតខំជួយកុមារវៀតណាមឱ្យរៀនភាសាខ្មែរ ស្របតាមការណែនាំលោកអភិបាល ដែលបានយកចិត្តទុកដាក់យ៉ាងខ្លាំងនៅលើផ្នែកអប់រំចំណេះទូទៅ ជាពិសេសរៀបចំព្រះសហគមន៍នេះឱ្យមានលក្ខណៈជាខ្មែរ។ លោកពេណ្ណាស៊ីអូ បានឱ្យដឹងថាៈ “នេះជាក្តីសប្បាយមួយ។ យើងរួបរួមគ្នានៅទីនេះក្នុងព្រះនាមព្រះយេស៊ូគ្រីស្ត ដោយបងប្អូនជាមិត្តសំលាញ់របស់ព្រះយេស៊ូ។ យើងជាមិត្តសំលាញ់នឹងគ្នា”។ លោកក៏បានពាំនាំនូវពាក្យអធិដ្ឋាន ការសួរសុខទុក្ខពីសម្តេចប៉ាបដល់បងប្អូនទាំងអស់គ្នាផងដែរ។ លី សុវណ្ណា

# ឆ្នាំអរព្រះគុណព្រះជាម្ចាស់

## លោកអភិបាលអេមីល ដេតម្បៈ “ឆ្នាំថ្មីនេះជាឆ្នាំអរព្រះគុណព្រះជាម្ចាស់” សម្រាប់ព្រះសហគមន៍កម្ពុជា ដែលទទួលដំណឹងល្អ បានរយៈ ៤៥០ឆ្នាំ។

## តែងតាំងបូជាចារ្យនៅវៀតណាម

កាលពីថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៥ គ្រីស្តបរិស័ទកាតូលិករាប់ពាន់នាក់បានចូលរួមក្នុងពិធីមួយដ៏ឱឡារិក ដែលជាការតែងតាំងលោកបូជាចារ្យថ្មីចំនួន ៥៧រូប សម្រាប់ភូមិភាគព្រះសហគមន៍ទាំង៨ នៃប្រទេសវៀតណាមភាគខាងជើង ធ្វើឡើងក្នុងវិសាលវិហារមួយនៃទីក្រុងហាណូយ រដ្ឋធានីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។
ពិធីនេះត្រូវបានរៀបចំឡើងក្រោមអធិបតីភាពរបស់លោកកាឌីណាល់មួយរូប មកពីបុរីវ៉ាទីកង់ ដែលជាសញ្ញានៃការធ្វើឱ្យបានប្រសើរឡើងនូវទំនាក់ទំនងរវាងរបបកុម្មុយនីស្ត និងបុរីវ៉ាទីកង់។ មានមនុស្សរាប់ពាន់នាក់បានប្រមូលផ្តុំនៅតាមដងផ្លូវរហូតដល់ច្រកចូលក្នុងព្រះវិសាលវិហារ និងជាច្រើនអ្នកទៀតបានឈរនៅលើយ៉ ឬដំបូលផ្ទះរបស់ពួកគេដើម្បីតាមដានពិធីនេះតាមរយៈសម្លេងដែលផ្សាយចេញពីឧគ្ឃោសនាសព្ទ។ គ្មានមន្ត្រីរដ្ឋាភិបាលវៀតណាមណាម្នាក់បានចូលរួមក្នុងពិធីនេះទេ។ ពិធីតែងតាំងនេះបានបង្ហាញឱ្យកាន់តែច្បាស់អំពីការចាប់កំណើតឡើងវិញនៃព្រះសហគមន៍នៅភាគខាងជើងប្រទេសបន្ទាប់ពីកន្លះសតវត្សរ៍នៃការរារាំងខាងនយោបាយ។
P.R

## ស្វាគមន៍កូនៗ


Photo: L. Sovanna

សាលាមត្តេយ្យចំនួន ៣កន្លែង ជាអំណោយរបស់ព្រះសហគមន៍កាតូលិក និងអង្គការ ស៊ី អេហ្វ ស៊ី ព្រមទាំងសប្បុរសជនសិង្ហបុរីសម្រាប់ភូមិពោធិ៍ធំ ភូមិក្តីកណ្តាល និងភូមិតាជោ នៃស្រុកល្វាឯម ខេត្តកណ្តាល បានបើកទ្វារទទួលកុមារឱ្យចូលរៀនលើកដំបូងក្រោមអធិបតីភាពលោកអភិបាល អេមីល ដេតម្បៈ។ លោកបានធ្វើកិច្ចស្វាគមន៍ដល់កូនៗទាំងអស់ និងបានថ្លែងអំណរគុណចំពោះអាជ្ញាធរដែនដីដែលបានអនុញ្ញាត។ សុវណ្ណា



## លក់ពេលនេះ CSC មានផលិត CD, VCD សាច់ភ្លេងអភិបូជា និងចម្រៀងណូអែល សូមអញ្ជើញរកជាវកុំបីខាន!



## មាគ៌ានៃការកែប្រែចិត្តគំនិត

កាលពីថ្ងៃទី៣០ វិច្ឆិកា ដល់ថ្ងៃទី០២ ខែធ្នូ ឆ្នាំ ២០០៥ នៅទេវវិទ្យាល័យ មានរៀបចំសិក្ខាសាលាពីមាគ៌ានៃការកែប្រែចិត្តគំនិត ដែលមានអ្នកចូលរួម ៣០នាក់។ អ្នកស្រីភ្លែង លី សាស្ត្រាចារ្យខ្មែរមកពីបារាំង បានណែនាំថា ព្រះរាជ្យព្រះអម្ចាស់គឺសម្រាប់សាសនាទាំងអស់ និងព្រះអង្គត្រាស់ហៅយើងឱ្យចូលរួមដូចព្រះអង្គ”។ គោលបំណងនៃអង្គសិក្ខាសាលាគឺឱ្យទាំងអស់គ្នាចេះកសាងខ្លួនឱ្យល្អ ស្គាល់សីលធម៌ និងចេះគោរពគ្នា និងគ្នា។

## ពិធីសុំចូលរួមក្នុងព្រះសហគមន៍

កាលល្ងាចថ្ងៃ ទី១៦ ធ្នូ ២០០៥ មានការប្រារព្ធពិធី ដែលបងស្រីនៃក្រុមមេត្តាករុណាព្រះគ្រីស្តមកពីវៀតណាមចំនួន ២នាក់ គឺបងស្រីម៉ារីធូ និងបងស្រីម៉ារីយឹងសុំអនុញ្ញាតចូលបម្រើព្រះសហគមន៍នៅភូមិភាគបាត់ដំបង។ បងស្រីម៉ារីធូ បានមានប្រសាសន៍ថាៈ “ខ្ញុំចង់រស់នៅកម្ពុជាជាងប្រទេសផ្សេងៗទៀត ពីព្រោះខ្ញុំចង់ក្លាយខ្លួនដូចជាអ្នកម្តាយតេរេហ្សាម៉្យាងនៅកម្ពុជានេះមានអ្នកនៅក្រីក្រច្រើនផង”។

## ណូអែលក្នុងពន្ធនាគារបាត់ដំបង

កាលព្រឹកថ្ងៃ ទី១៧ ធ្នូ ២០០៥ ព្រះសហគមន៍កាតូលិកខេត្តបាត់ដំបងមានរៀបចំកម្មវិធីណូអែលជាពិសេសសម្រាប់អ្នកទោសជាង៧០០នាក់ នៅក្នុងពន្ធនាគារខេត្ត។ ក្នុងនោះក៏មានចែកនូវនំបុ័ង និងសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនឱ្យអ្នកទោសដែរ។ បងស្រីការ៉ាមិន នៃសមាគមសាសនទូតមេត្តាករុណារបស់ព្រះយេស៊ូបានពោលថាៈ “ខ្ញុំមកសួរសុខទុក្ខបងប្អូននេះ ក៏ដូចជាខ្ញុំមកសួរសុខទុក្ខព្រះយេស៊ូដែរ”។


Photo: P. R

១ ធ្នូ

## អេដស៍: ៤០លាននាក់ រងការឆ្លង

របាយការណ៍របស់ភ្នាក់ងារអង្គការសហប្រជាជាតិទទួលបន្ទុកជំងឺអេដស៍បានបង្ហាញនូវស្ថានភាពកាន់តែធ្ងន់ជាងឆ្នាំកន្លងទៅ។ ចំនួនអ្នកផ្ទុកមេរោគអេដស៍លើពិភពលោកមានចំនួន ៤០,៣ លាននាក់ ធៀបនឹងឆ្នាំ ២០០៣ មានចំនួនតែ៣៧,៥លាន នាក់។ ជំងឺអេដស៍បានសម្លាប់មនុស្សប្រមាណជា ២៥លាននាក់ហើយ ចាប់ពីឆ្នាំ ១៩៨១មក។ នៅឆ្នាំ២០០៥ ក្នុងចំណោមអ្នកជំងឺអេដស៍ ៣,១លាននាក់ មាន ៥៧០០០០នាក់ គឺជាកុមារ។ អាមេរិកក្បែរសាហារ៉ា មានអ្នកផ្ទុកនិងអ្នកជំងឺអេដស៍ក្នុងចន្លោះពី ២៤ ទៅ២៩លាននាក់។ ៧៧ ％ នៃស្ត្រីអ្នកផ្ទុកមេរោគអេដស៍ គឺជាស្ត្រីជនជាតិអាហ្វ្រិក។
នៅប្រទេសចិន មនុស្ស ១០លាននាក់ កំពុងប្រឈមមុខនឹងការឆ្លងជំងឺចាប់ពីពេលនេះទៅដល់ឆ្នាំ ២០១០ ប្រសិនបើសកម្មភាពបង្ការរួសរាន់មួយមិនត្រូវបានគេជំរុញធ្វើឡើងទេនោះ។
នៅប្រទេសវៀតណាម ដោយឡែកតែនៅទីក្រុងហូជីមិញមានភាពលាយចម្រុះ ដោយការប្រើប្រាស់គ្រឿងញៀនចាក់តាមសរសៃឈាម និងការជួញដូរផ្លូវភេទ ដែលនាំមកនូវការឆ្លងរាតត្បាតដ៏ធ្ងន់ធ្ងរនៃជំងឺអេដស៍នៅពេលអនាគត។
បន្ទាប់ពីប្រទេសអាហ្វ្រិកខាងត្បូង គឺប្រទេសឥណ្ឌាដែលមានអ្នកផ្ទុកមេរោគអេដស៍ច្រើនបំផុត គឺ ៥,៦ លាននាក់ តួលេខឆ្នាំ២០០២។
នៅអាស៊ីអាគ្នេយ៍ មានកម្ពុជា ភូមា និងថៃ ការឆ្លងរាលដាលមានលក្ខណៈធ្ងន់ធ្ងរដោយឡែក។ នៅកម្ពុជា អត្រា អ្នកផ្ទុកមេរោគ និងកើតអេដស៍មានប្រហែល ៣％ គឺជាអត្រាខ្ពស់ជាងគេនៅអាស៊ី។
P.R

# កម្រងរូបថតសកម្មភាពព្រះសហគមន៍ថ្ងៃបុណ្យព្រះយេស៊ូប្រសូត!

## សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់!





១.រៀបចំកម្មវិធីកំសាន្តពេលរាត្រី។ ២.ទិដ្ឋភាពទូទៅរបស់ព្រះវិហារចំណោម។ ៣.ពិធីទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត។ ៤ ៥ ៦.កម្មវិធីសិល្បៈ និងរាំកំសាន្តនៅចំណោម។ ៧.អំណរសប្បាយអបអរសាទរព្រះយេស៊ូប្រសូតនៅចំណោម។



ទិដ្ឋភាពទូទៅនាពេលរាត្រីបុណ្យព្រះយេស៊ូប្រសូតនៅក្នុង បរិវេណព្រះសហគមន៍បាត់ដំបង





១.ច្រៀងលើកតម្កើងព្រះជាម្ចាស់ក្នុងអភិបូជា នៅបាត់ដំបង។ ២.ប័ណ្ណជូនពរបុណ្យព្រះយេស៊ូប្រសូត។ ៣.សម្តែងពីព្រះយេស៊ូប្រសូត។ ៤.បាចទឹកព្រះពរ។ ៥.ដង្ហែព្រះកុមារយេស៊ូចូលក្នុងព្រះវិហារ ៦.ថ្វាយបង្គំព្រះកុមារយេស៊ូ។ ៧.អានព្រះគម្ពីរ។



Photos: L. Sovanna, M. Kunthear, P. Samphy



ព្រះសហគមន៍កំពង់ចាម : ១.លោកបូជាចារ្យសេរ៉ាលដ៏ អានព្រះគម្ពីរដំណឹងល្អ។ ២.ខ្លោងទ្វារចូលព្រះសហគមន៍កំពង់ចាម។ ៣.ការបង្ហាញប្រាប់ភ្ញៀវអំពីផែនទីភូមិភាគព្រះសហគមន៍ទាំងបីនៅកម្ពុជា។ ៤.ការតាំងលក់វត្ថុអនុស្សាវរីយ៍។ ៥.ការសម្តែងអំពីពិធីទទួលអគ្គសញ្ញាជ្រមុជទឹក។ ៦.ទស្សនាការសម្តែងរឿងព្រះយេស៊ូប្រសូត។ ៧.ការរាំលេងកំសាន្តរបស់យុវជន។ ៨.ថតរូបអនុស្សាវរីយ៍ជាមួយតាណូអែល។





ព្រះសហគមន៍ចំការទៀង ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ : ១.ទស្សនិកជនមើលឆាកសម្តែងសិល្បៈ។ ២.យុវជនសម្តែងរឿងទុំទាវ។ ៣.យុវជនឡើងច្រៀងកំដរឆាក។ ៤.សម្តែងរឿងទុំទាវ។ ៥.ពិធីករ-ការិនីនៅក្នុងកម្មវិធីចាប់ឆ្នោតផ្សងសំណាង។ ៦.រង្វាន់សម្រាប់ឆ្នោតមានទូរទស្សន៍ និងវត្ថុផ្សេងៗ ទៀត។ ៧.លោកបូជាចារ្យអូលីវីយេ ដឹកនាំបងប្អូនថ្វាយបង្គំព្រះយេស៊ូ។ ៨.គ្រីស្តបរិស័ទអុជធុបសុំសេចក្តីសុខ។

ការប្រកាសដំណឹងល្អ គឺជាភារកិច្ចរបស់គ្រីស្តបរិស័ទម្នាក់ៗ ក្រោមការបំភ្លឺរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ គ្រីស្តបរិស័ទម្នាក់ៗ ត្រូវរស់នៅ និងធ្វើជាសក្ខីភាពនៃសេចក្តីស្រលាញ់ដើម្បីបញ្ជាក់អំពីវត្តមានរបស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់ខ្លួន។

# ២៤នាក់ ចូលក្នុងព្រះសហគមន៍



លោកអគ្គរាជទូតធ្វើការប្រគល់ឈើឆ្កាងដល់អ្នកដែលស្វែងយល់

Photo: L. Sovanna

ជាផលផ្លែនៃការផ្តល់សក្ខីភាព នៃសេចក្តីស្រលាញ់ និងការប្រកាសដំណឹងល្អរបស់ព្រះសហគមន៍កាតូលិក មានបងប្អូនចំនួន ២៤នាក់ បានសុំចូលព្រះសហគមន៍កាតូលិក នាឱកាសពិធីសម្ពោធព្រះវិហារថ្មីរបស់សន្តហ្វ្រង់ស្វ័រសាវីយេ នៅព្រះសហគមន៍កអណ្តើក ឃុំប្រាសាទ ស្រុកកំពង់ត្របែកនៃខេត្តព្រៃវែងកាលពីថ្ងៃ ទី៣ ធ្នូ ឆ្នាំ២០០៥ កន្លងទៅនេះ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់អគ្គរាជទូតសម្តេចប៉ាបប្រចាំនៅកម្ពុជា គឺលោកសាលវ៉ាទ័រ ពេណ្ណាស៊ីអូ ។

នៅក្នុងពិធីនេះ យើងសង្កេតឃើញមាន វត្តមានរបស់លោកអភិបាលទាំងបីភូមិភាគ លោកបូជាចារ្យ បងស្រី ព្រមទាំងគ្រីស្តបរិស័ទ បងប្អូនអ្នកស្វែងរក និងអាជ្ញាធរដែនដីចូលរួមយ៉ាងច្រើនកុះករ។ ពិធីបានចាប់ផ្តើម លោកអគ្គរាជទូតបានមានប្រសាសន៍ថា លោកមានសេចក្តីរីករាយខ្លាំងដោយមានកិត្តិយសមកជួបជុំបងប្អូនអ្នកស្វែងយល់នៅក្នុងពិធីសម្ពោធព្រះវិហារថ្មី និងពិធីបងប្អូនទទួលជំហាន ទី១ នេះ។ លោកបន្ថែមថា: "បងប្អូនបានត្រៀមខ្លួនអស់រយៈពេល ៣ឆ្នាំ មកហើយ"។ លោកសូមអធិដ្ឋានសម្រាប់បងប្អូន សូមឱ្យព្រះជាម្ចាស់ប្រទានជំនឿ និងសេចក្តីសង្ឃឹម ដើម្បីបន្តរហូតដល់ថ្ងៃទទួលអគ្គសញ្ញាជ្រមុជទឹក និងនៅថ្ងៃអនាគត។

ព្រះសហគមន៍ កអណ្តើក ជាព្រះសហគមន៍ថ្មីមួយ បានចាប់ផ្តើមឡើងដោយការខិតខំស្វែងយល់អំពីព្រះបន្ទូលរបស់បងប្អូនដែលព្រះជាម្ចាស់បានជ្រើសរើសនៅក្នុងចំណោមបងប្អូនពុទ្ធបរិស័ទខ្មែរយើង។ លោកមុំ ប៊ុនធឿន បានបង្ហាញអំពីក្តីរំភើបរបស់លោកថា លោកមានសេចក្តីអំណរណាស់ ដោយបានទទួលជំហាន ទី១ ថ្ងៃនេះ ព្រោះលោករង់ចាំរយៈពេលយូរឆ្នាំមកហើយ។ បុរសវ័យកណ្តាលរូបនេះបានបញ្ជាក់អំពីមូលហេតុ ដែលធ្វើឱ្យលោកចង់ស្វែងយល់ពីព្រះបន្ទូលរបស់ព្រះយេស៊ូថា: "គឺដោយសារលោកមើលឃើញអំពីសក្ខីភាព និងការស្រលាញ់របស់គ្រីស្តបរិស័ទចំពោះរូបលោក ពិសេសចំពោះអ្នកជំងឺ អ្នកក្រីក្រ និងអ្នកគ្មានទីពឹង"។ សម្រាប់ទៅថ្ងៃអនាគត លោកនឹងខិតខំបន្តនូវសក្ខីភាពអំពីព្រះយេស៊ូឱ្យដល់អស់បងប្អូនដទៃទៀតឱ្យស្គាល់ព្រះអង្គ ព្រមទាំងទទួលការសង្គ្រោះពីព្រះអង្គផងដែរ។

លោកស្រី ពុធ ដែលបានទទួលដំណឹងល្អ តាមរយៈលោក មុំ ប៊ុនធឿន បានប្រាប់ឱ្យដឹងថា: "ព្រះបន្ទូលបានធ្វើឱ្យ ខ្ញុំមានការកែប្រែ និងបើកចិត្តគំនិតចំពោះអ្នកដទៃ" ដែលនេះក៏ធ្វើឱ្យលោកស្រីចេះយកចិត្តទុកដាក់ចំពោះអ្នកជំងឺ ឬអ្នកគ្មានទីពឹងផងដែរ និងជាពិសេសជួយឱ្យលោកស្រីចេះលះបង់ដើម្បីព្រះសហគមន៍ និងបងប្អូនឯទៀតៗ។

នៅក្នុងធម្មទេសនាលោកអភិបាល អេមីល មានប្រសាសន៍សង្កត់ធ្ងន់ថា: "ជំនឿពុំមែនមកពីការខិតខំរបស់យើងនោះទេ តែនេះជាព្រះអំណោយទានរបស់ព្រះជាម្ចាស់"។

ចំណែកឯលោកអគ្គរាជទូត បានផ្តាំផ្ញើដល់បងប្អូន ដែលទើបនឹងទទួលជំហាន ទី១ ថា: "បងប្អូនមានព្រះវិហារ ដែលសង់ពីថ្ម និងស៊ីម៉ង់ត៍ គឺមានន័យថា ព្រះសហគមន៍ថ្មីនេះ កសាងពីថ្មដែលមានជីវិត និងសេចក្តីស្រលាញ់ និងពីស៊ីម៉ង់ត៍ ដែលផ្សារភ្ជាប់ព្រះសហគមន៍ឱ្យកាន់តែរឹងមាំ"។ លោកបានប្រាប់ពីការសួរសុខទុក្ខ និងការអធិដ្ឋាន នៃសម្តេចប៉ាបបេណេឌីកទី១៦ សម្រាប់បងប្អូនព្រះសហគមន៍ នៅកម្ពុជា និងសូមអរព្រះគុណដល់ព្រះជាម្ចាស់ ដែលណែនាំឱ្យមាន អ្នកនាំដំណឹងល្អដំបូងបង្អស់សម្រាប់ប្រទេសនេះ តាំងពី ៤៥០ឆ្នាំមុន។

លី សុវណ្ណា

## ព្រះសហគមន៍ កអណ្តើក

បានចាប់ផ្តើមឡើងនៅឆ្នាំ ២០០២ ដោយមានការប្រមូលផ្តុំជួបជុំគ្នាដំបូងដោយអតីតយុវនិស្សិតមហាវិទ្យាល័យសេដ្ឋកិច្ចមួយរូប។ លោក មុំ ប៊ុនធឿន បានឱ្យដឹងថា "ការជួបជុំដំបូង គឺគ្មានអ្នកអប់រំជំនឿនោះទេ"។ លោកបានទាក់ទងនឹងព្រះសហគមន៍ជាញឹកញាប់ ប៉ុន្តែមិនបានសម្រេចទេដោយលោកមិនមែនជាគ្រីស្តបរិស័ទ។ លុះដល់ឆ្នាំ ២០០២ លោកបានទាក់ទងជាមួយលោកអភិបាលអន់ តូនី និងចាប់ទទួលការអប់រំជំនឿរហូតមកដល់សព្វថ្ងៃនេះ និងបានកសាងព្រះវិហារដោយយកសន្តហ្វ្រង់ស្វ័រសាវីយេ ជាឧបការី"។





# សុភមង្គលគ្រួសារស្ថិតនៅឯណា?

មនុស្សទាំងអស់កើតមកមានវាសនាខុសៗគ្នា។ អ្នកខ្លះមានសំណាង ឯខ្លះទៀតជួបតែការលំបាក។ តើធ្វើយ៉ាងណាទើបទុក្ខកង្វល់ទាំងនោះលែងមានទៀត? អ្នកនាំសារ សូមលើកយកបញ្ហាមួយចំនួន និងមានអ្នកប្រឹក្សាចូលរួមជួយដោះស្រាយ។



រូបលំអ: ការសាកសួរសុខទុក្ខញាតិចាស់ទុំគឺជាផ្នែកនៃការរឹតចំណងទាក់ទងរវាងសមាជិកគ្រួសារ

Photo: L. Sovanna

**តើធ្វើយ៉ាងដើម្បីឱ្យជីដូនយល់អំពីតម្លៃនៃការសិក្សា?**

ស្រីដា ត្រូវបានយាយនាងបង្ខំឱ្យឈប់រៀនដើម្បីធ្វើការរោងចក្រ។ យាយនាងតែងតែរអ៊ូ និងមួម៉ៅដាក់នាងជានិច្ច។

**សាស្ត្រាចារ្យ ផាន់ ចាន់ពៅ:** ប្អូនគួរតែធ្វើនូវសកម្មភាព ឬអំពើឱ្យគាត់មើល ជំនួសការនិយាយស្តី ពីព្រោះគាត់ពុំបានយល់ពីអ្វីដែលយើងបាននិយាយជាមួយគាត់ទេ ដោយចំណេះដឹងរបស់គាត់នៅទាប។ អ៊ីចឹង! បើចង់ឱ្យគាត់យល់ពីតម្លៃនៃការសិក្សា យល់ពីចិត្តប្អូន ប្អូនត្រូវធ្វើឱ្យគាត់ឃើញថា ដោយសារចំនេះដឹង ប្អូនអាចរកចំណូលមកផ្គត់ផ្គង់ក្នុងគ្រួសារ បានដោយស្រួល។ ពេលនោះគាត់អាចវាយតម្លៃថា ការសិក្សារបស់យើង មិនមែនឥតប្រយោជន៍នោះទេ។ ប៉ុន្តែពេលនេះ ប្អូនត្រូវមានការតស៊ូ និងអត់ធ្មត់បន្តិចហើយ។

**តើធ្វើយ៉ាងម៉េចដើម្បីបញ្ចៀសជម្លោះរវាងបងប្អូន?**

វណ្ណា តែងត្រូវបងស្រីវាយធ្វើបាប ពីព្រោះគាត់ចូលចិត្តទៅមើលគេលេងល្បែង។ គាត់បានលួចលុយម្តាយគាត់ជាង ១ ម៉ឺនរៀល ដើម្បីទៅលេងឡុកឡាក់។ ក្រោយមកគាត់មានការភិតភ័យ រហូតគាត់សម្រេចលេបថ្នាំសម្លាប់ខ្លួន ប៉ុន្តែត្រូវបានគេជួយទាន់។ ចាប់ពីពេលនោះ គាត់ក៏ឈប់លេងល្បែងទៀត ប៉ុន្តែ បងស្រីនៅតែធ្វើបាបគាត់រហូត ធ្វើឱ្យម្តាយមានការពិបាកចិត្ត ដោយសារតែកូនៗ។

**សាស្ត្រាចារ្យ ផាន់ ចាន់ពៅ:** ជាទូទៅមិនមែនសុខៗមានជម្លោះកើតឡើងនោះទេ ជួនកាលបងស្រីវណ្ណាធ្វើការហត់ ឬក៏គាត់ត្រូវរងការស្តីបន្ទោសពីថ្នាក់លើ។ គាត់បែរជាផ្ទេរកំហឹងមកអ្នកក្រោមបង្គាប់គាត់។ នេះជាធម្មជាតិមួយដែលយើងពិបាកនឹងចៀសណាស់។ បើយើងជាប្អូនប្រុសជាទីស្រលាញ់ម្នាក់របស់គាត់ គាត់ក៏មិនអាចផ្ទេរកំហឹង មកឱ្យយើងបានទេ ប្រហែលជាយើងមានចំនុចខ្លះ ដែលធ្វើឱ្យគាត់មិនពេញចិត្ត។ ដូច្នេះវណ្ណាគួរតែបង្កើតនូវភាពសប្បាយមួយដែលធ្វើឱ្យគាត់អាចនឹងស្រលាញ់យើងបាន។ នៅពេលគាត់សប្បាយចិត្ត យើងគួរនិយាយជាមួយគាត់ថា ថ្ងៃក្រោយ បើបងខឹង បងគួរតែផ្ទេរការខឹងនោះ ដោយទៅស្រែកនៅខាងក្រៅ ឬធ្វើអ្វីមួយផ្សេងវិញ ជាការប្រសើរជាង ។

**តើធ្វើយ៉ាងណាដើម្បីកុំឱ្យមានអារម្មណ៍តូចចិត្តខ្លួនឯងនៅពេលម្តាយស្តីបន្ទោស?**

ម្តាយពិសីគឺជាមនុស្សកាច និងតែងស្តីបន្ទោសឱ្យនាង ទោះបីនាងខំធ្វើការងារយ៉ាងណាក្តី។

**សាស្ត្រាចារ្យផាន់ ចាន់ពៅ:** មិនមានវិធីសាស្ត្រ ធ្វើមិនឱ្យមានការតូចចិត្តទេ ប៉ុន្តែមានវិធីសាស្ត្រ ធ្វើឱ្យម្តាយមិនស្តីឱ្យ។ បញ្ហាចម្បងក្នុងក្រុមគ្រួសារពិសី គឺជាបញ្ហាហិរញ្ញវត្ថុ។ អ្នកទទួលបន្ទុកការងារក្នុងគ្រួសារ គឺជាអ្នកដែលតែងត្រូវស្តីបន្ទោស។ ដូច្នេះវាមានន័យថា អ្នកម្តាយបានចាត់ទុកពិសី គឺជាមនុស្សចាស់ម្នាក់ គឺជាអ្នកដែលគាត់អាចជេរស្តីបាន អាចជជែកជាមួយបាន គឺមានតែពិសី ពីព្រោះពិសីគឺជាអ្នកទទួលរ៉ាប់រងនៅក្នុងសង្គមគ្រួសារច្រើនជាងគេ។ ពិសីអាចបំភ្លេចការស្តីបន្ទោសឱ្យនេះ ហើយបើពិសីអាចរក្សាអាកប្បកិរិយាប្រឈមមុខជាមួយនិងបញ្ហានេះ បែបធម្មតាៗ បានជារៀងរហូត នោះរឹតតែប្រសើរ។ នៅពេលដែលហិរញ្ញវត្ថុនៅក្នុងគ្រួសារមានកំណើននោះ ពិសីនឹងមានសុភមង្គលមិនខាន។

ទំនាក់ទំនងកម្មវិធី ០១៦ ៣២៦៧៣៧

## កម្មវិធីវិទ្យុព្រះសហគមន៍

ការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍ បានរៀបចំនូវកម្មវិធីវិទ្យុពីរសម្រាប់បម្រើប្រិយមិត្ត។ ទីមួយ "យុវជនសម័យទំនើប!" ចាក់ផ្សាយនៅវិទ្យុគ្រួសារ FM 99.5 MHz ម៉ោង ១៣:៣០នាទី និងផ្សាយឡើងវិញម៉ោង ២០:៣០នាទី រៀងរាល់ថ្ងៃសៅរ៍នៅរាជធានីភ្នំពេញ។ ទីពីរកម្មវិធី "អេម៉ាណូអែល" ចាក់ផ្សាយក្នុងវិទ្យុ FM 91.5 MHz ម៉ោង ៦:៣០នាទីរៀងរាល់ថ្ងៃសៅរ៍ នៅទីរួមខេត្តបាត់ដំបង។

# ការអភិវឌ្ឍន៍ទាមទារនូវការចូលរួមពីស្ត្រី

បច្ចុប្បន្ន នៅក្នុងជួររដ្ឋាភិបាល អង្គការ ឬសហគ្រាសមួយចំនួន មានស្ត្រីជាអ្នកដឹកនាំបានយ៉ាងល្អ ដែលអាចនិយាយបានថា ស្ត្រីបំពេញការងារបានពូកែជាងបុរសមួយចំនួនទៀតផង។ នេះគឺគ្រាន់តែជាជ្រុងមួយរបស់ស្ត្រីប៉ុណ្ណោះ។ ម៉្យាងវិញទៀត ក៏មានបុរសមួយចំនួនបានសរសើរស្ត្រីរហូតដល់លាន់មាត់ថា: "ស្រីៗឥឡូវពុំធម្មតាទេ"។


Photo: DR
ប្រធានអង្គការស្ត្រីខ្មែរចុះសួរសុខទុក្ខប្រជាជននៅតាមសហគមន៍

**តើការអភិវឌ្ឍន៍សង្គមរបស់ស្ត្រីដូចបុរស ?**

ឥឡូវនេះ ស្ត្រីបានចូលរួមការងារក្នុង គ្រប់វិស័យ ប៉ុន្តែគ្រាន់តែថា នៅមានកត្តាមួយចំនួន ដែលមិនបានលើកតម្កើង ឬរំលេចស្ត្រីមកនៅខាងក្រៅ។ ម៉្យាងទៀត ស្ត្រីគឺគ្រាន់តែជាអ្នកចូលរួម ក្នុងការអនុវត្តន៍ផ្ទាល់ ឯការសំរេចចិត្ត គាត់ពុំសូវបានចូលរួមទេ។ លោកស្រីរស់ សុភាព ជានាយិកាអង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា បានពោលថា: "ការចូលរួមរបស់ស្ត្រីក្នុងការអភិវឌ្ឍន៍ប្រទេសពុំស្មើនឹងបុរស ប៉ុន្តែស្ត្រីជាភាគី ឬក៏ជាផ្នែកមួយ ដ៏ចាំបាច់បំផុតនៅក្នុងកិច្ចអភិវឌ្ឍន៍។ ស្ត្រីមានគ្រប់បរិបទ និងគ្រប់ផ្នែកក្នុងដំណើរការអភិវឌ្ឍន៍"។

តាមរយៈនេះលោកស្រីមួរ សុខហួរ អតីតរដ្ឋមន្ត្រីក្រសួងកិច្ចការនារីបានឱ្យដឹងថា ដើម្បីលុបបំបាត់បញ្ហាទាំងនេះ យើងត្រូវមានកម្មវិធីបំពាក់បំប៉នជួយជំរុញឱ្យស្ត្រីយល់ថាអ្វីទៅជាការដឹកនាំ។ ការជំរុញស្ត្រីឱ្យចូលក្នុងការងារសាធារណៈ ឬភាពជាអ្នកដឹកនាំ យើងត្រូវមាននូវកម្មវិធីពិសេស ដើម្បីជួយទ្រទ្រង់ និងជូនដំណើរនៅគ្រប់ជំហាន។

**តើមានកម្រិត ឬគំលាតការងារយ៉ាងម៉េចខ្លះរវាងបុរស និងស្ត្រី?**

លោកហោ ទង បុគ្គលិកនៃអង្គការទស្សនៈពិភពលោកបានឱ្យដឹងថា ស្ត្រីជាអ្នកដឹកនាំមួយដ៏ល្អមិនថាតែនៅក្នុងសង្គម និងគ្រួសារឡើយ។ ម៉្យាងទៀត បច្ចុប្បន្ននេះ រដ្ឋាភិបាលកំពុងតែផ្តោតការយកចិត្តទុកដាក់សំខាន់ទៅលើ Gender ដែលស្ត្រីធ្វើអ្វីៗបានដូចជាបុរសដែរ។

លោកស្រីជា វណ្ណាត ប្រធានមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ក៏បាននិយាយថា: "ស្ត្រីមានតួនាទីក្នុងការអភិវឌ្ឍន៍សង្គមដូចគ្នានឹងបុរស គឺមានន័យថា បើបុរសអាចធ្វើអ្វីបាន ក៏ស្ត្រីអាចធ្វើបានដូចគ្នា ពីព្រោះបុរស និងស្ត្រីជាដៃគូនឹងគ្នាសម្រាប់កិច្ចការដើម្បីអភិវឌ្ឍប្រទេសជាតិ។

លោកស្រី រស់ សុភាព បានឱ្យដឹងដែរថា បន្ទាប់ពីបានធ្វើការពិគ្រោះយោបល់ស្តីពីការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយក៏ដូចជាកិច្ចអភិវឌ្ឍន៍ ឃើញថា បើសិនយើងធ្វើការប្រៀបធៀប រវាងការដឹកនាំរបស់ស្ត្រី ជាមួយបុរស ឃើញថា ការដឹកនាំរបស់ស្ត្រី មានលក្ខណ:ទន់ភ្លន់ និងចេះបត់បែន។ ម៉្យាងទៀត ស្ត្រីយល់អំពីការងារបានម៉ត់ចត់ និងលំអិតជាង។ ស្ត្រីមិនជ្រើសរើសយកអំពើហិង្សាមកដោះស្រាយបញ្ហាទេ។ ដូច្នេះ ស្ត្រីមានបែបផែនក្នុងការអនុវត្តន៍ ដែលការអនុវត្តន៍របស់ស្ត្រីច្រើនផ្អែកលើការចូលរួមច្រើនជាង។

លោកស្រីមួរ សុខហួរថ្លែងថា គំលាតនេះក៏មកពីសង្គម និងទំនៀមទំលាប់ដែរ ដោយយល់ឃើញថា ស្ត្រីគួរតែនៅផ្ទះធ្វើកិច្ចការងារ និងឆាប់ឱ្យស្ត្រីរៀបការ នៅពេលដែលពួកគេកំពុងរៀន។ ប៉ុន្តែសម្រាប់ការអភិវឌ្ឍន៍សង្គម គឺគេតែងត្រូវការនូវធនធានមនុស្ស ដែលមានចំនេះដឹងច្រើន។ ដូច្នេះ វាគឺជាឧបសគ្គចំពោះការឈោងទៅធ្វើជាអ្នកនយោបាយ ព្រោះទទួលរងនូវបញ្ហាច្រើន។

លោកស្រី រស់ សុភាព បាននិយាយថា គ្មានកន្លែងដែលស្ត្រីធ្វើការ ស្មើនឹងបុរសទេ។ ស្ត្រីធ្វើការនៅព្រឹទ្ធសភា មានប្រហែល ១០-១២% សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ មានតែ ៨% ស្ត្រីជារដ្ឋមន្ត្រី មានតែម្នាក់ ឬពីរនាក់ ដូច្នេះ គ្មានការងារណាស្មើគ្នានឹងបុរសឡើយ។ ហើយស្ត្រីចូលរួមក្នុងការដឹកនាំគឺមិនដល់ ១៥% ផង។ តែបើស្ត្រីនៅធ្វើការងារផ្សេងៗ ដូចជា ការធ្វើស្រែ លក់អីវ៉ាន់ រកចំណូលឱ្យគ្រួសារ គឺស្ត្រីមានច្រើនជាងបុរស។

**មានឧបសគ្គអ្វីកើតឡើងបើគ្មានស្ត្រីចូលរួម?**

លោកស្រីប៉ែន វិកស៊ី ប្រធានអង្គការស្ត្រីខ្មែរមានប្រសាសន៍ថា: "ការកសាងប្រទេសមួយមិនអាចដំណើរការទៅបានទេ បើគ្មានស្ត្រី។ ស្ត្រីមានចំនួនច្រើនដែរ ដែលមានជំនាញ និងសមត្ថភាពពុំចាញ់បុរសនោះ។ បើគ្មានស្ត្រីមានន័យថា ជាតិមិនបានប្រើប្រាស់នូវធនធានមនុស្ស ដែលមានស្រាប់ ឱ្យអស់"។ ឯលោកស្រីចក់ មើល ជាប្រធានមន្ទីរកិច្ចការនារីខេត្តរតនគិរី បានមានប្រសាសន៍ថា: "អ្វីដែលជាឧបសគ្គដល់សង្គមនោះគឺនៅពេលដែលពុំមានស្ត្រីចូលរួមការងារអភិវឌ្ឍន៍។ បុរស និងស្ត្រីត្រូវតែដើរទៅទន្ទឹមគ្នា"។

**ស្ត្រីបង្វិលចង្ក្រានមិនជុំស្ថិតក្នុងអារម្មណ៍ស្ត្រី?**

គំនិត "ស្ត្រីបង្វិលចង្ក្រានមិនជុំ" គឺនៅតែចាក់ឬសយ៉ាងជ្រៅក្នុងអារម្មណ៍នៃស្ត្រី និងបុរស។ ម្យ៉ាងសង្គមពុំសូវឱ្យតម្លៃស្ត្រី ដែលធ្វើឱ្យពាក្យនេះ នៅតែមាន។ ការអភិវឌ្ឍន៍ប្រទេសជាតិដែលបានរីកចម្រើនមកដល់សព្វថ្ងៃនេះ ក៏ដោយសារមានការចូលរួមចំណែកដ៏សំខាន់ពីស្ត្រីដែរ។ ក្នុងន័យនេះ លោកស្រីរស់ សុភាព បានលើកឡើងថា: "យើងអាចមើលឃើញការរួមចំណែករបស់ស្ត្រីក្នុងការអភិវឌ្ឍន៍ជាតិ ដូចជា ស្ត្រីធ្វើការកម្មកររោងចក្រដែលមានប្រមាណ ៩០%។ ពួកគាត់មិនមានការអប់រំខ្ពស់ ប៉ុន្តែបាននាំមកនូវថវិកាដល់ជាតិ ច្រើនណាស់ក្នុងមួយឆ្នាំៗ។ គេមិនបានមើលគាត់ ថាជាមនុស្សសំខាន់ដោយទុកពួកគាត់នៅជ្រុងម្ខាង"។

អត្ថបទដោយមុំ គន្ធា

## ចំនួនស្ត្រីបម្រើការងារដូចបុរស

ក្នុងចំណោមសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ចំនួន ១១២៦១រូប មានស្ត្រី ៩៨៣រូប តួលេខឆ្នាំ២០០២។ សមាជិកព្រឹទ្ធសភាទាំងអស់ចំនួន ៦១រូប មានស្ត្រី ៨រូបកំពុងបំពេញការងារ។ ចំណែកឯនៅក្នុងរដ្ឋសភាវិញក្នុងចំណោមតំណាងរាស្ត្រចំនួន ១២៣រូប មានស្ត្រីចំនួន ១៩រូប។ រីឯក្នុងជួររដ្ឋាភិបាល មានស្ត្រី ២រូប ធ្វើជារដ្ឋមន្ត្រី និង ៨រូបទៀត ធ្វើជារដ្ឋលេខាធិការ។



# ព្រះសហគមន៍កាតូលិកបានកំពុងយកចិត្តទុកដាក់លើស្ត្រី

"យេនឌ័រជាតួនាទីមួយ ដែលសង្គមដាក់មកឱ្យស្ត្រីធ្វើជាម្តាយ ថែរក្សាកូន ធ្វើម្ហូប ឯបុរសមាននាទីរកលុយចិញ្ចឹមគ្រួសារដោយមិនឱ្យបុរសនៅក្នុងចង្ក្រានទេ គឺឱ្យស្ត្រីនៅក្នុងចង្ក្រាន"។

ចំពោះបញ្ហាស្ត្រីព្រះសហគមន៍យើង ក៏បានធ្វើការងារជាច្រើនជួយដល់ស្ត្រីៗ ដូចជា ការផ្តល់ការងារដើម្បីផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ ជាដើម តែ ការងារនេះមិនបានបង្ហាញខ្លាំង ដូចជានៅតាមអង្គការទេ ដោយយើងធ្វើទៅតាមសមត្ថភាពនៃព្រះសហគមន៍។ ជាក់ស្តែង មណ្ឌលព្រះសហគមន៍ខេត្តព្រៃវែង ដែលជាខេត្តមួយដែលមានភាពក្រីក្រជាងគេ បានជួយដល់ស្ត្រីចំនួន ៨នាក់ ដែលមានជីវភាពក្រីក្រ និងគ្មានលទ្ធភាពក្នុងការរៀនបន្ត ឱ្យបានរៀនសូត្រ។

បងស្រីសង្ឃាតនៃព្រះសហគមន៍ខេត្តព្រៃវែង បានទៅពិនិត្យមើលអំពីគ្រួសាររបស់ក្មេងស្រីដែលមានជីវភាពក្រលំបាកពិតៗតែម្តង ដែលពួកគេមិនមានលទ្ធភាពបន្តការសិក្សា។ ពេលនោះបងស្រី និងលោកឪពុកអាល់បេតូបានធ្វើការទាក់ទងយកក្មេងស្រីទាំង៨នាក់នោះ មករស់នៅក្នុងមណ្ឌលព្រះវិហារខេត្តព្រៃវែង និងជួយពួកគេឱ្យបានរៀនសូត្របន្ត។

បងស្រីបានមានប្រសាសន៍ថា:"បើយើងគិតពីតុល្យភាពនៅក្នុងសាលា ចំនួនស្ត្រី គឺនៅចាញ់ប្រុសៗ ពីព្រោះប្រុសៗមានសមត្ថភាព អាចចេញទៅបន្តការសិក្សានៅតាមកន្លែងឆ្ងាយៗបាន ដោយសារគេអាចស្នាក់នៅតាមវត្ត ឬក៏កន្លែងណាក៏បាន"។ បងស្រីបានបន្តថា ស្រីៗគឺមានភាពលំបាក ដែលធ្វើឱ្យព្រះសហគមន៍ដូចជាព្រះសហគមន៍ព្រៃវែងនេះជាដើម ជួយដល់ពួកគេដើម្បីឱ្យពួកគេអាចបន្តការសិក្សាតទៅទៀត។ មិនតែប៉ុណ្ណោះ ព្រះសហគមន៍នៅខេត្តព្រៃវែង បានធ្វើការជួយដល់ស្ត្រីៗ ជាច្រើននាក់ទៀត តាមរូបភាពផ្សេងៗ មានដូចជាស្ត្រីមេម៉ាយ ស្ត្រីមានជំងឺ និងស្ត្រី ដែលមានជីវភាពក្រីក្រខ្សត់ខ្សោយជាដើម។

ក្នុងន័យនេះព្រះសហគមន៍ធ្វើការលើកស្ទួយអំពីតម្លៃមនុស្ស តម្លៃនៃជីវិត និងពន្យល់គេឱ្យស្គាល់ថា ជីវិតមនុស្សម្នាក់ៗ មានតម្លៃ ឱ្យគេគោរពជីវិត និងស្គាល់ពីតម្លៃជីវិតខ្លួន។ ដូចនេះ ការជួយពួកគេ ជារបៀបមួយតាមគ្រីស្តសាសនា ដែលទាក់ទងទៅនឹងផ្លូវចិត្ត ពីព្រោះយើងចង់ជួយពួកគេឱ្យដឹងពីតម្លៃ និងឧបសគ្គនៃជីវិត។ ជាច្រើនដង យើងបានធ្វើការអប់រំដល់ស្ត្រីៗ ពិសេសនារីក្មេងៗ ដោយអប់រំពួកគេតាមរយៈផ្លូវចិត្ត ដោយឱ្យពួកគេរៀនរស់នៅក្នុងសង្គម ចេះស្រលាញ់ការសិក្សា ហើយ និងស្គាល់អំពីតម្លៃរបស់ខ្លួនឯងផងដែរ។

បងស្រីបានសំណូមពរថា យើងគួរមានកម្មវិធីខ្លះៗ ដើម្បីជួយស្ត្រីឱ្យហ៊ាននិយាយ និងហ៊ានបញ្ចេញយោបល់។ បងស្រីបន្តថា ព្រះសហគមន៍ព្រៃវែងមានគម្រោង នឹងសុំដល់អង្គការផ្សេងៗ ឱ្យជួយអប់រំដល់ក្មេងៗ ស្រីៗ ឱ្យចេះពីរបៀបទំនាក់ទំនងរវាងវ័យ និងវ័យដែរ។


Photo: M. Kunthear
បងស្រីសង្ឃាតនៃព្រះសហគមន៍ព្រៃវែង

# តើឆ្អឹងមានតួនាទីអ្វី?







...

# តើឆ្អឹងមានតួនាទីអ្វី?

ដោយសារតែឆ្អឹង យើងអាចឈរត្រង់ខ្លួនៈ បើគ្មានឆ្អឹងទេនោះ ខ្លួនមនុស្សនឹងមានសភាពទន់ជ្រាយ ដូចជាសត្វខ្យងឥតសំបក!



## ឆ្អឹងខ្លះ មានតួនាទីជាអ្នកការពារ

១. ឆ្អឹងលលាដ៍មានតួនាទីការពារខួរក្បាល។
២. ឆ្អឹងជំនីរការពារបេះដូង និងសួត។
៣. ឆ្អឹងខ្នងការពារ ខួរឆ្អឹងខ្នង។
(ដែលជាអ្នកបញ្ជូនព័ត៌មានពីសរសៃប្រសាទយើងទៅកាន់ខួរក្បាល)។

## ឆ្អឹងគឺអាងបម្រុងជីវិត

នៅក្នុងឆ្អឹង មានផ្ទុកទៅដោយខួរឆ្អឹង។ ខួរឆ្អឹងជាអ្នកបង្កើតគ្រាប់ឈាមក្រហម ដែលមានតួនាទីដឹកជញ្ជូនអុកស៊ីសែនទៅកាន់គ្រប់ទីកន្លែងនៅក្នុងរាងកាយ គ្រាប់ឈាមស ដែលមានតួនាទីអ្នកការពារជំងឺ ហើយនិងប្លាស្មាដែលជួយឱ្យឈាមកកក្នុងករណីរងរបួស។



## ខ្ញុំនៅតែមានមាឌតូចជាងគេជានិច្ចនៅក្នុងថ្នាក់!

មាឌតូចមិនអាចរារាំងអ្នកមិនឱ្យក្លាយជាអ្នកកំប្លែងដ៏ល្បីល្បាញ មិនឱ្យក្លាយជាអ្នក ដែលមានទឹកចិត្តពោរពេញដោយសេចក្ដីស្រលាញ់ មិនអាចរារាំងអ្នកមិនឱ្យមានមិត្តភក្តិច្រើន ពីព្រោះពួកគេស្រលាញ់រូបអ្នកដោយសារគុណសម្បត្តិដ៏ច្រើនរបស់អ្នក!

សូមកុំភ្លេចថាៈ ជាញឹកញាប់ណាស់ មនុស្សដែលមានមាឌល្អិតបានក្លាយទៅជាមនុស្សដ៏ល្បីល្បាញ។ ឧទាហរណ៍ជាក់ស្ដែង ណាប៉ូឡេអុងបានក្លាយជាព្រះចៅអធិរាជរបស់ជនជាតិបារាំងនៅឆ្នាំ១៨០៣ ជាដើម!



## ពពួកឆ្អឹង ដែលមានទំហំធំៗ



នៅជើងមានឆ្អឹង ២៧
នៅដៃមានឆ្អឹង ២៦

## ឆ្អឹងបីតូចជាងគេបំផុត គឺនៅក្នុងត្រចៀកៈ

ឆ្អឹងញញួរ
ឆ្អឹងដែកទ្រនាប់
និងឆ្អឹងឈ្នាន់កែបសេះ។





ព្រះសហគមន៍នៅកម្ពុជាមានប្រវត្តិសាស្ត្រយូរលង់ណាស់មកហើយ ប៉ុន្តែដើម្បីស្វែងយល់ឱ្យបានកាន់តែច្បាស់ថែមទៀត ហើយទន្ទឹមនឹងពេលមានចម្ងល់មួយចំនួនរបស់ប្រិយមិត្តអ្នកអានអំពីព្រះសហគមន៍ផងនោះ។ អ្នកនាំសារ សូមលើកយកនូវសំណួរផ្សេងៗមកចោទ ដោយមានលោកបូជាចារ្យ អ៊ីវ៉ាន់ អាស្លី ជាអ្នកបកស្រាយក្នុងខ្លឹមសារដូចតទៅ:

# ស្វែងយល់អំពីព្រះសហគមន៍របស់យើង



រូបលំអៈ ការជួបជុំរបស់បងប្អូនគ្រីស្តបរិស័ទ និងបូជាចារ្យដើម្បីអធិដ្ឋាននៅព្រះសហគមន៍កាតូលិកស្រែស្បូវ

**តើព្រះសហគមន៍កាតូលិកមាននៅកម្ពុជាតាំងពីពេលណា? នរណាជាអ្នកបង្កើត? និងមានដំណើរការយ៉ាងដូចម្ដេច?**

នៅសតវត្សរ៍ទី១៦ មានបូជាចារ្យអេស្ប៉ាញញ៉ុលមួយចំនួនចូលមកប្រទេសកម្ពុជា។ ក្រោយមកក៏មានគ្រីស្តបរិស័ទជនជាតិជប៉ុនភៀសខ្លួន មកនៅប្រទេសខ្មែរ ព្រោះនៅជប៉ុនសម័យនោះ ក្រោយពេលសន្ត ហ្វ្រង់ស្វ័រសាវៀរ ធ្វើការផ្សព្វផ្សាយនូវដំណឹងល្អ ក៏ទទួលការជិះជាន់ពីថ្នាក់ដឹកនាំ ដូច្នេះពួកគេភៀសខ្លួនមកនៅប្រទេសខ្មែរ។ បន្ទាប់មកទៀត ជនជាតិប័រទុយហ្គាល់ក៏មកដែរ ហើយរៀបការជាមួយស្ត្រីខ្មែរ ក៏មានកូនកាត់។ តាំងពីពេលនោះមក ក៏ចាប់មានគ្រីស្តបរិស័ទខ្មែរ រស់នៅក្នុងប្រទេសខ្មែរ។ សតវត្សរ៍ទី១៧-១៨ ក៏មានបូជា-ចារ្យជនជាតិបារាំងជួយ ឱ្យព្រះសហគមន៍ខ្មែររីកចម្រើនរហូតមកដល់សព្វថ្ងៃនេះ។

**តើហេតុអ្វីបានជាបុណ្យណូអែលមានការផ្ញើកាដូ ឬក៏លិខិតជូនពរគ្នា?**

ណូអែលជាបុណ្យរំឭកអំពីសេចក្ដីស្រលាញ់ ដែលបានមកពីព្រះជាម្ចាស់ គឺជាហេតុដែលនាំឱ្យយើងសម្ដែងសេចក្ដីស្រលាញ់ សាជាថ្មី ដល់ឪពុកម្ដាយបងប្អូន និងអ្នកឯទៀតៗ។ នៅពេលទទួលកាដូ យើងមិនមែនផ្ដោតអារម្មណ៍តែទៅលើរបស់ទាំងនោះទេ យើងផ្ដោតអារម្មណ៍លើសេចក្ដីស្រលាញ់ ដែលគេសម្ដែងមកលើយើង ហើយយើងសម្ដែងការសប្បាយចំពោះគេវិញ។ នេះជារឿងសំខាន់។ រីឯរឿងកាដូនេះ វាគ្រាន់តែជានិមិត្តរូបនៃសេចក្ដីស្រលាញ់រវាងគ្នា និងគ្នាប៉ុណ្ណោះ។

**តើកាដូអ្វីដែលជាកាដូពិសេសបំផុតសម្រាប់ជូនឱ្យគ្នាទៅវិញទៅមក?**

ជាធម្មតា នៅពេលដែលយើងជ្រើសរើសកាដូ ឬរបស់អ្វីមួយសម្រាប់មនុស្ស ដែលយើងស្រលាញ់ យើងគួរជ្រើសរើសអ្វីមួយ ដែលគេត្រូវការ ឬគិតថា គេនឹងពេញចិត្ត។ យើងត្រូវតែរិះគិតពីបំណងប្រាថ្នារបស់គេ បានសេចក្ដីថា យើងត្រូវស្គាល់គេឱ្យបានច្បាស់។ នៅពេលដែលអ្នកនោះទទួលកាដូរបស់យើង ទោះបីជាគេពេញចិត្ត ឬមិនពេញចិត្ត ក៏គេគិតថា យើងយកចិត្តទុកដាក់ចំពោះគេ ដែលធ្វើឱ្យគេមានអំណរសប្បាយដែរ។

**សន្តក្លូសជានរណា? ហេតុអ្វីមានសន្តក្លូស?**

តាមពិត នៅព្រះសហគមន៍ពីមុន មានសន្តបុគ្គលម្នាក់ឈ្មោះសន្ត នីកូលាស់នៅប្រទេសទួរគី។ គេបានគោរពសន្ត នីកូលាស់ នេះខ្លាំងណាស់ តែនៅពេលសាសនា អ៊ីស្លាម រីកចម្រើន រាលដាលដល់ប្រទេសទួរគី គេក៏បានយកឆ្អឹង និងធ្មេញរបស់សន្តនីកូលាស់នេះយកមកប្រទេសអ៊ីតាលីវិញ រួចបង្កើតព្រះវិហារធំសម្រាប់សន្ត នីកូលាស់។ តាំងពីពេលនោះ ប្រជាជនជឿថា សន្ត នីកូលាស់ គឺជាអ្នកស្រលាញ់កូនក្មេង មនុស្សខ្វិនខ្វាក់ ស្ត្រីពេស្យា និងមនុស្សក្រោសង្គមផងដែរ។ គេតែងអធិដ្ឋានអង្វរចំពោះសន្ត នីកូលាស់ ឱ្យជួយថែរក្សាខ្លួន។ ស្រាប់តែពេលជនជាតិហូឡង់ទៅអាមេរិក យើងបានបាត់ដំណឹងពីសន្ត នីកូលាស់ បានក្លាយទៅជា [illegible]

CSC

## សំណួរនៅកម្មវិធីក្រោយ

តើរូបផ្កាយតំណាងឱ្យអ្វីពេលបុណ្យព្រះយេស៊ូប្រសូត? តើព្រះសហគមន៍កាតូលិកមានគោលដៅយ៉ាងណាចំពោះសាសនាដទៃជាពិសេស សាសនាព្រះពុទ្ធ ជាសាសនារដ្ឋ? តើព្រះយេហូវ៉ាជានរណា? បញ្ជាក់: ប្រិយមិត្តក៏អាចផ្ញើសំនួរអំពីចម្ងល់ខ្លួនអំពីអ្វីមួយ មកការិយាល័យ អ្នកនាំសារ តាមរយៈលោកបូជាចារ្យ បងប្រុស ឬបងស្រីដែលនៅជិតអ្នកបំផុត។ សូមអរគុណ!

# បងស្រីតេរេហ្សា និងជីវិតស្ងប់ស្ងាត់ក្នុងក្រុមបងស្រីសម្ងាត់

ចម្រៀងលើកតម្កើងព្រះអម្ចាស់ បានផុសចេញពីបន្ទប់នៃអគារពណ៌ផ្កាឈូកយ៉ាងស្រស់ស្អាតមួយ និងមានសម្លេងយ៉ាងពីរោះរងំ ដែលចេញពីក្រុមបងស្រីសម្ងាត់ ៦នាក់ កំពុងអង្គុយអធិដ្ឋាន។ ក្នុងនោះ ក៏មានបងស្រីសម្ងាត់ តេរេហ្សា របស់ក្រុមកាមែល ដែលទើបតែនឹងមកពីទីក្រុងសេអ៊ូលនៃប្រទេសកូរ៉េខាងត្បូងផងដែរ។ ក្នុងឯកសណ្ឋានពណ៌ខ្មៅវែងតាំងពីក្បាលដល់ចុងជើង និងបន្សល់តែរង្វង់មុខ បងស្រីតេរេហ្សា ជាប្រធានក្រុមបងស្រីសម្ងាត់នៅរាជធានីភ្នំពេញ ក៏បាននិយាយថា: "ខ្ញុំបានសម្រេចចិត្តចូលក្រុមដួនជីសម្ងាត់ ព្រោះខ្ញុំស្រឡាញ់ និងចង់អធិដ្ឋានដល់ព្រះជាម្ចាស់"។

បងស្រីតេរេហ្សាបានចូលរួមនៅក្នុងក្រុមអ្នកបួសនៃបងស្រីកាមែល តាំងពីអាយុ ២៥ឆ្នាំ ដែលមកដល់ពេលនេះ មានរយៈពេល ៦ឆ្នាំកន្លះហើយ។ បងស្រីពោលបន្តថា នេះគឺជាការត្រាស់ហៅរបស់ព្រះជាម្ចាស់តាមរយៈនៃការអានសៀវភៅ ដែលនិយាយអំពីជីវិតអ្នកបួសក្រុមបងប្រុសសម្ងាត់។ ក្រោយមក បងស្រីបានចាប់សុំយោបល់ ពីលោកបូជាចារ្យនៅព្រះសហគមន៍របស់គាត់។ បន្ទាប់ពីលោកបូជាចារ្យបានអនុញ្ញាត គាត់ក៏សាកល្បង។ ចាប់តាំងពីពេលនោះមក គាត់បានឃើញនូវការត្រាស់ហៅពិតប្រាកដមែន។ មុនដំបូង គឺមានការប្រឆាំងពីម្តាយខ្លាំងមែនទែន។ ប៉ុន្តែក្រោយមក ម្តាយគាត់យល់រឿង ហើយក៏ឱ្យសេរីភាពកូន។

ទឹកមុខកំពុងរិះគិត បងស្រីពោលថា: "នៅពេលខ្ញុំចូលក្នុងអារាមបងស្រីសម្ងាត់ដំបូង ខ្ញុំមានការសប្បាយរីករាយខ្លាំងលើចំនុចពិសេសមួយ គឺការអធិដ្ឋាន"។ រៀងរាល់ថ្ងៃ ខ្ញុំអធិដ្ឋាន ៧ដង តាមកាលវិភាគ"។ ចំពោះការងារប្រចាំថ្ងៃ ដែលបងស្រី និងក្រុមធ្វើ មានដូចជា ដាំបន្លែសម្រាប់ញ៉ាំ និងលក់ខ្លះៗ។ ការងារទាំងនេះ បងស្រីតេរេហ្សាធ្វើក្នុងនាមព្រះជាម្ចាស់ និងតែងនឹកគិតពីវត្តមានរបស់ព្រះជាម្ចាស់ជានិច្ច។ បងស្រីតេរេហ្សាក៏បានបន្តថា: "ខ្ញុំចងចាំបានថា ទម្រាំមកដល់ចំនុចនេះ ខ្ញុំបានឆ្លងកាត់ដំណាក់កាលមួយដ៏ពិបាកមែនទែន នោះគឺការអស់សង្ឃឹម។ ដំបូង ខ្ញុំមិនចង់រស់នៅរបៀបនេះទៀតទេ ពីព្រោះជីវិតមានការលំបាកខ្លាំងគ្មានសេរីភាព។ ខ្ញុំចង់ត្រឡប់ទៅផ្ទះវិញ តែដំណាក់កាលនោះមានរយៈពេលខ្លីប៉ុណ្ណោះ"។



បងស្រីតេរេហ្សាកំពុងធ្វើការអធិដ្ឋានសម្រាប់ប្រទេសកម្ពុជា

Photo: H.Ioktheary

បងស្រីតេរេហ្សា នឹងរស់នៅប្រទេសកម្ពុជារហូតដើម្បីធ្វើអធិដ្ឋានសម្រាប់ប្រទេសនេះ ជាពិសេសសម្រាប់ស្ត្រី។ បងស្រីជឿថាស្ត្រីខ្មែរអាចផ្លាស់ប្តូរប្រទេសឱ្យមានការរីកចម្រើន ដូចមានពាក្យមួយឃ្លាពោលថា: "ស្ត្រីគឺជាមាតាពិភពលោក"។

ហ៊ូ សុខធារី

## មតិលោកអភិបាល អេមីល ដេតម្ប

លោកអភិបាលបានយល់ឃើញថា ក្នុងរយៈពេល ១៥ឆ្នាំនេះ ព្រះសហគមន៍យើងមិនត្រឹមតែត្រូវការអ្នកជួយធ្វើសកម្មភាពសម្រាប់ជនក្រីក្រប៉ុណ្ណោះទេ តែយើងក៏ត្រូវការអ្នកជួយអធិដ្ឋានសម្រាប់សកម្មភាពព្រះសហគមន៍យើងដែរ។ សូមរំឭកផងដែរថា ពីឆ្នាំ១៩១៣ ដល់១៩៧៥ នៅកម្ពុជាក៏មានបងស្រីសម្ងាត់ប្រហែល ១៥នាក់ ដែលរស់នៅអារាមជ្រោយចង្វា ទីក្រុងភ្នំពេញ។

## ព្រឹត្តិការណ៍នឹងមាន!

- ថ្ងៃទី០៥ មករា: រៀបចំបុណ្យរំឭកខួបលើកទី២១៦ នៃព្រះសហគមន៍បាត់ដំបង។
- ថ្ងៃទី០៧ មករា ២០០៦: មានរៀបចំពិធីជប់លៀងសម្រាប់ក្មេងអនាថានៅព្រះសហគមន៍កំពង់ចាម។
- ថ្ងៃទី០៨ មករា: ជំនួបនិសិត្សកាតូលិកស្តីអំពីប្រធានបទ "យើងរួមគ្នាជាកម្លាំងព្រះសហគមន៍" ប្រារព្ធធ្វើឡើងនៅសាលាដុនបូស្កូទឹកថ្លា ភ្នំពេញ។ ទាក់ទងតាមទូរស័ព្ទរបស់លោកបូជាចារ្យអេនរីកូ ០១២ ៨៥០ ១៦០។
- ថ្ងៃទី១០ មករា: ជំនួបរបស់លោកបូជាចារ្យ ដូនជី និងគ្រូអប់រំជំនឿមនុស្សពេញវ័យលើប្រធានបទ "រិះគិតនិងចាត់ចែងកម្មវិធីសម្រាប់អប់រំ មនុស្សពេញវ័យឱ្យបានច្បាស់លាស់" នៅកំពង់សោម។
- ថ្ងៃទី១៥ មករា : តែងតាំងលោកលីចាង វ៉ុន (Lichang Won) ជាឧបដ្ឋាកនៃក្រុមសមាគមសាសនទូតកូរ៉េ នៅព្រះសហគមន៍ផ្សារតូច ភ្នំពេញ។
- ថ្ងៃទី២៩ មករា: នៅព្រះសហគមន៍កំពង់ចាម មានការរៀបចំជាសិក្ខាសាលាស្វែងយល់អំពីជីវិតផ្លូវភេទតាមរបៀបគ្រីស្តសាសនារបស់យុវជនកាតូលិក។
- ថ្ងៃទី៣០ មករា: សិក្ខាសាលាស្វែងយល់អំពីជីវិតផ្លូវភេទតាមរបៀបគ្រីស្តសាសនាចំពោះឪពុកម្តាយរបស់យុវជនកាតូលិក នៅព្រះសហគមន៍កំពង់ចាម។

ការិយាល័យផ្សព្វផ្សាយ
ព័ត៌មានព្រះសហគមន៍កាតូលិក
ផ្ទះលេខ ២៥ ផ្លូវលេខ ២៨២ សង្កាត់
បឹងព្រលិត ខណ្ឌ ៧មករា រាជធានី ភ្នំពេញ
Tel/Fax: (855) 23 224 120 E-mail:
csc@catholiccambodia.org & Website:
www.catholiccambodia.org
អភិបាលគ្រប់គ្រង: លោកអភិបាល
អេមីល ដេតម្ប អគ្គនាយក: លោកបូជាចារ្យ
ហែរណាន់ ពីនីឡា